

# ការធ្វើតេស្តរកមើលមេរោគ HIV

## ស្ត្រីនិងមេរោគ HIV: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្តីអំពីមេរោគ HIV



ការទើបតែបានរកឃើញមានមេរោគថ្មីៗ



ការព្យាបាលផ្សេងៗៈ កត្តាសំខាន់ ។



ការមើលថែទាំខ្លួនអ្នក



ការមានផ្ទៃពោះ និង ខ្ញុំ



កិច្ចបំរើផ្សេងៗ រដ្ឋ NSW និង គេហទំព័រ

### មានវិធីតែមួយដើម្បីអោយដឹង

HIV គឺជាមេរោគដែលបណ្តាលអោយមានជំងឺ អេដស៍ (AIDS) ថ។ មនុស្សជាច្រើនមិនដឹងថា ខ្លួនមានមេរោគ HIV ផង។ មានវិធីតែមួយ ដើម្បីអោយដឹងថាលោកអ្នកមានមរោគ HIV គឺការធ្វើតេស្តឈាម។ នៅពេលមនុស្សម្នាក់មានមេរោគ HIV គឺគេថា ពួកគេមានមេរោគ HIV វិជ្ជមាន។

### ខ្ញុំជាស្ត្រី តើហេតុអ្វីបានខ្ញុំត្រូវធ្វើតេស្ត ?

មនុស្សដែលមេរោគ HIV លើពិភពលោកពាក់កណ្តាល គឺជា ស្ត្រី។ នៅប្រទេសអូស្ត្រាលីមានស្ត្រីប្រហែលជា ១៥០០នាក់ផ្ទុកមេរោគ HIV។អ្នកខ្លះឆ្លងមេរោគ HIV ពីដៃគូដែលរស់នៅជាមួយ គ្នារាល់ថ្ងៃឬអតីតដៃគូ។ កត្តាចំបងដែលបង្កគ្រោះថ្នាក់នៃការចម្លងមេរោគ HIV ចំពោះស្ត្រីនៅប្រទេសអូស្ត្រាលីមាន:

- រួមដំណេកជាមួយអ្នកដែលមកពីប្រទេសដែលមានមេរោគ HIV អត្រាខ្ពស់
- ការប្រើម្ជុល និងឧបករណ៏ចាក់ថ្នាំរួមគ្នា។

មេរោគ HIV ឆ្លងតាមរយ:

- ការរួមដំណេកដោយមិនប្រុងប្រយ័ត្ន (ការរួមដំណេកដោយមិនប្រើស្រោមអនាម័យ)ជាមួយ អ្នកមានមេរោគ HIV
- ការប្រើម្ជុល និងឧបករណ៏ចាក់ថ្នាំរួមគ្នា
- ម្តាយឆ្លងទៅកូននៅពេលមានផ្ទៃពោះ ពេលឆ្លងទន្លេ ឬពេលបំបៅកូនដោយទឹក ដោះម្តាយ
- ការបញ្ចូលឈាមក្នុងប្រទេសខ្លះ។ ការផ្តល់ឈាមក្នុងប្រទេសអូស្ត្រាលីត្រូវបានគេពិនិត្យមេរោគ HIV តាំងពីឆ្នាំ១៩៨៥។

ប្រសិនបើលោកអ្នក សង្ស័យថាមានមេរោគ HIV គួរគិតពីការធ្វើតេស្ត។ ប្រសិនបើលោកអ្នកត្រូវបានគេពិនិត្យឃើញថាមានមេរោគ HIV វិជ្ជមាន លោកអ្នកអាចនឹងថែរក្សាសុខភាពខ្លួនអោយបានប្រសើរ។ គេអាចទប់ស្កាត់មេរោគ HIV ដោយការព្យាបាលហើយមនុស្សជាច្រើន អាចរស់នៅដោយមានសុខភាពល្អនិងមមាញឹកក្នុងជីវិត។ ប្រសិនបើលោកអ្នកមានផ្ទៃពោះ ឬមានគំរោងចង់បានកូនមានមធ្យោបាយ ដែលមានប្រសិទ្ធិភាពជាច្រើនដែលអាចជួយ បន្ថយគ្រោះថ្នាក់នូវការឆ្លង មេរោគ HIV ទៅទារកលោកអ្នក។

### អំពីការធ្វើតេស្ត

ការធ្វើតេស្តHIV គឺជាការធ្វើតេស្តឈាម ដែលគេពិនិត្យរកមើលអង្គបដិបក្ខ HIV នៅក្នុងឈាម។ អង្គបដិបក្ខត្វូវបន បង្កើតឡើងដោយប្រព័ន្ធសុំាក្នុងខ្លួននៅពេលលោកអ្នករលាកឬឆ្លងនូវ មេរោគ។ បើលទ្ធផលនៃការធ្វើតេស្តចេញវិជ្ជមាន វេជ្ជបណ្ឌិតនឹងសូមធ្វើតេស្តបន្ថែមទៀតដើម្បី បញ្ជាក់ពី លទ្ធផល។ វាអាចចំណាយពេលរហូតដល់ទៅ១២សប្តាហ៍ ដីម្បីអោយរាងកាយផលិត នូវអង្គបដិបក្ខនេះ។

នេះគេហៅថារយៈពេលមិនទាន់កំណត 'window period' ។ មានន័យថា បើលោកអ្នកទើបតែឆ្លង មេរោគថ្មីៗ ប្រហែលវាមិនអាចបង្ហាញអោយឃើញនូវមេរោគ ពេលធ្វើតេស្តលើកទីមួយនោះទេហើយប្រហែលជាគេអោយធ្វើតេស្តម្តងទៀត បន្ទាប់ពីបីខែ។

### តើខ្ញុំអាចធ្វើតេស្តនៅទីណា?

លោកអ្នកអាចសុំធ្វើតេស្តនៅវេជ្ជបណ្ឌិតប្រចាំគ្រួសារពីមជ្ឈមណ្ឌលគំរោងគ្រួសារនៅរដ្ឋ NSW និងករណីខ្លះទៀត នៅមន្ទីសុខភាពផ្លូវភេទ។

វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាអាចនិយាយជាមួយលោកអ្នក អំពីភាពខុសគ្នារវាង HIV និង AIDS ព្រមទាំងរបៀបឆ្លង ហើយអ្វីនឹងកើតឡើងនៅពេល លោកអ្នកទទួលលទ្ធផល។

FAMILY PLANNING NSW
www.fpnsw.org.au

acon
BUILDING OUR COMMUNITY'S HEALTH & WELLBEING

Multicultural HIV/AIDS and Hepatitis C Service

HIV + HETEROSEXUALS

ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែមិថុនា 2009

ពួកគេអាចសួរនូវសំនួរផ្ទាល់ខ្លួន ដើម្បីអោយដឹងពីកំរិតនៃស្ថានភាពជំងឺ របស់លោកអ្នក។ នេះគេហៅថា “ការពិភាក្សាមុនពេលធ្វើតេស្ត” ហើយ ក៏ជាឱកាសសំរាប់លោកអ្នកអាចសួរសំនួរ។

លោកអ្នកមិនចាំបាច់ធ្វើការសំរេចចិត្តធ្វើតេស្តនៅថ្ងៃព្រមគ្នានោះទេ គឺអាចសួរពិភាក្សាជាច្រើនដងមុននឹងធ្វើការសំរេចចិត្ត។ វេជ្ជបណ្ឌិត មិនត្រូវធ្វើតេស្ត ដោយគ្មានការអនុញ្ញាតិពីលោកអ្នកឡើយ។ វាគឺជាការសំរេចចិត្តរបស់លោកអ្នក ក្នុងការធ្វើតេស្តឬអត់ហើយលោកអ្នកអាចធ្វើការជ្រើសរើសយកវេជ្ជបណ្ឌិតណាដែលលោកអ្នកទុកចិត្ត។

លទ្ធផលតេស្ត នឹងត្រូវគេអោយលោកអ្នកផ្ទាល់ ទោះជាលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមានក្តី។ ប្រសិនបើលទ្ធផលចេញថា HIV វិជ្ជមាន វេជ្ជបណ្ឌិតត្រូវផ្តល់ពត៌មានលំអិត បន្ថែមពីកិច្ចបំរើជួយគាំទ្រ ផ្សេងៗ រួមទាំងកិច្ចបំរើសំរាប់ស្ត្រីមានមេរោគ HIV ផងដែរ។ លោកអ្នកអាចទាក់ទងទៅលេខដែលមានរាយឈ្មោះនៅខាងស្តាំ អំពីកិច្ចបំរើក្នុងរដ្ឋណស៊្វ និងតាមគេហទំព័រ នៃក្រដាសពត៌មាន។

## ការរក្សាការសំងាត់

តាមច្បាប់បានចែងថា វេជ្ជបណ្ឌិតនិងបុគ្គលិកផ្នែកថែទាំសុខភាពដទៃទៀត នៅប្រទេសអូស្ត្រាលីត្រូវតែរក្សាការសំងាត់របស់លោកអ្នក។
មានន័យ ថាពួកគេមិនអាច និយាយពីបញ្ហាផ្ទាល់ខ្លួនរបស់លោកអ្នកទៅប្រាប់អ្នកដទៃទៀតឡើយលុះត្រាតែមានការអនុញ្ញាតពីអ្នក។



## កិច្ចបំរើផ្សេងៗ

លោកអ្នកក៏អាចរកមើលកិច្ចបំរើនានាតាមកិច្ចបំរើ នៃរដ្ឋ ណស៊្វ និងតាមគេហទំព័រក្រដាសពត៌មាន

គំរោងគ្រួសាររដ NSW (Family Planning)

បណ្តាញសុខភាព (Healthline) ទូរស័ព្ទ :1300 658 886

បណ្តាញពត៌មានសុខភាពផ្លូវភេទតាមរដ្ឋ NSW (NSW Sexual Health InfoLine)

ទូរស័ព្ទដោយឥតគិតថ្លៃ 1800 451 624

បណ្តាញពត៌មានមេរោគ HIV (HIV information line)

ទូរស័ព្ទដោយឥតគិតថ្លៃ 1800 451 600

ប្រសិនបើលោកត្រូវការអ្នកបកប្រែ សូមទូរស័ព្ទលេខ: 131 450

សំរាប់ការអានបន្ថែម: សូមបើគេហកទំព័រខាងក្រោម ឬសួររកឯកសារពីបុគ្គលិកជួយគាំទ្រចម្លើយនូវសំនួរដែលគេឧស្សាហ៍សួរអំពី

HIV/AIDS(Answers to the most Frequently Asked Questions about HIV/AIDS)

បណ្តាញពត៌មាន HIV/AIDS (HIV/AIDS Information Line)

www.sesiahs.health.nsw.gov.au/albionstcentre/documents/pdfdocs/HIV_FAQ_Booklet_August_2006.pdf

ខ្ញុំមានផ្ទៃពោះ តើខ្ញុំត្រូវការធ្វើតេស្ត HIV ទេ?
(I'm pregnant, do I need an HIV test?)

ពត៌មានមានជាភាសាអង់គ្លេស និងភាសាដទៃទៀត

www.multiculturalhivhepc.net.au

ការធ្វើតេស្តរកមើលមេរោគ HIV



ស្ត្រីនិងមេរោគ HIV: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្តីអំពីមេរោគ HIV

ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែមិថុនា 2009